# ប្រឡងឆមាសលើកទី១
## វិញ្ញាសាៈ ភាសាខ្មែរ

**សាលាបឋមសិក្សា** …………………….
**ថ្នាក់ទី៦**
**ឈ្មោះ**……………………………………….

| ពិន្ទុ | មូលវិចារ |
| --- | --- |
| | |

**I. អំណាន**

ចូរអ្នកអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ។

### រឿង ទំនៀមទម្លាប់ដាក់ប្រាក់កាក់នៅក្នុងមាត់អ្នកស្លាប់

មានរឿងបុរាណតំណាលតៗគ្នាថា មានបុរសម្នាក់នៅជាមួយប្រពន្ធតាំងពីក្មេងរហូតដល់ចាស់ គ្មានកូនមួយសោះ។ គាត់មានមាសមួយបាត។ ប្ដីប្រពន្ធនេះ បានសន្យាគ្នាថា បើអ្នកណាស្លាប់មុនត្រូវយកមាសនេះ ដាក់ក្នុងមាត់អ្នកនោះ។ ចំណេរកាលមិនយូរប៉ុន្មាន ប្ដីបានស្លាប់មុនទៅ។ ភរិយាក៏យកមាសនោះទៅដាក់ក្នុងមាត់ប្ដី ហើយយកសពប្ដីទៅបូជា។ ភ្លើងឆេះមាសរលាយអស់នៅសល់តែបីស្លឹង។

ថ្ងៃមួយ ព្រះមហាក្សត្របានត្រាស់បង្គាប់ឱ្យរៃអង្គាសមាសក្នុងមួយផ្ទះឱ្យបានមួយបាតជាកំហិត។ ប្រពន្ធរបស់ខ្មោចនោះ ក៏យកមាសបីស្លឹងដែលគាត់រើសទុកនោះ ទៅថ្វាយស្ដេច។ គាត់ទូលស្ដេច ៖ “ ក្រាបទូលព្រះករុណា! មាសនេះពីដើមពេញមួយបាត តែខ្ញុំម្ចាស់បានយកទៅបង់មាត់ឱ្យប្ដីខ្ញុំម្ចាស់នៅពេលគាត់ស្លាប់ ក៏ត្រូវភ្លើងឆេះអស់នៅសល់តែប៉ុណ្ណឹង។ សូមព្រះករុណា មេត្តាដល់សត្វទ័លក្រផងចុះ។ ខ្ញុំម្ចាស់មិនអាចរកមាសមកថ្វាយព្រះអង្គបានឡើយ”។ ព្រះមហាក្សត្រទ្រង់ស្ដាប់ហើយ ក៏កើតក្ដីសង្វេគស្លុតព្រះទ័យ ទើបទ្រង់លើកលែងការរៃយកមាសពីបណ្ដារាស្ត្រតទៅទៀត។

អាស្រ័យរឿងនេះ ទើបបណ្ដារាស្ត្រទាំងអស់យល់ថា ប្រាក់ ឬមាសដែលបង់ក្នុងមាត់ខ្មោច មានអានុភាពទៅលើទឹកចិត្តមនុស្សណាស់ សូម្បីព្រះមហាក្សត្រក៏ចុះចាញ់អានុភាពនេះដែរ។ ម្យ៉ាងទៀត អានុភាពនៃប្រាក់ ឬមាសបង់មាត់ខ្មោចនេះ ជាវត្ថុស័ក្តិសិទ្ធិអាចជួយរំដោះគ្រោះថ្នាក់ ក្នុងពេលមានអាសន្នបាន។ ហេតុដូច្នេះហើយ ទើបគេនាំគ្នាធ្វើរបៀបនេះ រហូតកើតទៅជាទំនៀមទម្លាប់តរៀងមក។

ប៉ុន្តែអ្នកប្រាជ្ញបុរាណ ឱ្យយកប្រាក់ ឬមាសទៅដាក់ក្នុងមាត់ខ្មោច ដើម្បីធ្វើជាប្រស្នាឱ្យពិចារណាថា យើងមិនអាចយករបស់អ្វីមួយជាប់នឹងខ្លួនបានទេ នៅពេលដែលយើងស្លាប់ទៅ។

**(ដកស្រង់នឹងកែសម្រួលពីប្រជុំរឿងព្រេងខ្មែរភាគ៩)**

**សំណួរ**

១. តើរឿងនេះមានតួអង្គណាខ្លះ?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

២. តើប្ដីប្រពន្ធបានសន្យាគ្នាដូចម្ដេច?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

LIVEWORKSHEETS

៣. តើព្រះមហាក្សត្រត្រាស់បង្គាប់ដូចម្ដេច?

............................................................................................................................................

............................................................................................................................................

៤. ហេតុអ្វីបានជាព្រះមហាក្សត្រឈប់រែអង្គាសមាសពីប្រជារាស្ត្រ?

............................................................................................................................................

............................................................................................................................................

៥. តើប្រជារាស្ត្រ មានជំនឿដូចម្ដេចចំពោះការយកប្រាក់ ឬមាសទៅបង់នឹងមាត់ខ្មោច?

............................................................................................................................................

............................................................................................................................................

៦. តើអ្នកប្រាជ្ញបុរាណចង់អប់រំដូចម្ដេច?

............................................................................................................................................

............................................................................................................................................

**II. លំហាត់**

**ក. ចូររកពាក្យន័យដូចនឹងពាក្យខាងដើមជួរ ដោយគូសសញ្ញា √ ក្នុងប្រអប់ និង x ក្នុងប្រអប់ចម្លើយខុស។**

១. ប្រព្រឹត្ត ៖ ☐ ចូលចិត្ត ☐ ធ្វើតាម ☐ ប្រឹងប្រែង

២. ប្រហារ ៖ ☐ ខឹង ☐ ចង ☐ សម្លាប់

៣. គន្លង ៖ ☐ លំអាន ☐ របង ☐ ព្រំប្រទល់ ។

**ខ. ចូររកពាក្យពីរដែលមានន័យដូចគ្នានៅក្នុងជួរនីមួយៗ ។**

១. ត្រកាល ៖ ☐ ប្រសើរ ☐ ប្រយ័ត្ន ☐ ថ្លៃថ្នូ

២. ដេរដាស៖ ☐ ប្រញឹក ☐ ពាសពេញ ☐ រីរក់

៣. ត្រកាល ៖ ☐ បៀតបៀន ☐ ប្រមាថ ☐ ប្រមូល ។

**គ. ចូររកពាក្យផ្ទុយនឹងពាក្យខាងដើមជួរ ដោយគូសសញ្ញា √ ក្នុងប្រអប់ និង x ក្នុងប្រអប់ចម្លើយខុស។**

១. សាមគ្គី ៖ ☐ រួបរួម ☐ បែកបាក់ ☐ រៀចរេវ

២. អ៊ូអរ ៖ ☐ ខ្វល់ខ្វាយ ☐ មមាញឹក ☐ ប្រមូល ។

**ឃ. ចូររកពាក្យដែលមានន័យផ្ទុយគ្នានឹងពាក្យនៅក្នុងជួរនីមួយៗ ។**

១. បុរាណ ៖ ☐ យូរ ☐ សម័យ ☐ ចាស់

២. សរសើរ ៖ ☐ បន្ទុះបង្អាប់ ☐ ញញើត ☐ កោតក្រែង

៣. អន់ថយ ៖ ☐ ជុះជាល ☐ រួសរាយ ☐ ជឿនលឿន

៤. ទុកចិត្ត ៖ ☐ ប្រយ័ត្ន ☐ ធ្វេសប្រហែស ☐ ជឿជាក់

៥. ហូរហៀរ៖ ☐ ចង្អៀត ☐ ញឹកញាប់ ☐ ម្តងម្កាល ។

LIVEWORKSHEETS

**ង. ចូរយកពាក្យក្នុងប្រអប់ទៅបំពេញចន្លោះខាងក្រោម ។**

| | | | | | | | |
|---|---|---|---|---|---|---|---|
| ឧទ្ទិស | ព្រះពុទ្ធ | ព្រះសង្ឃ | ជំនឿ | ចង្ហាន់ | សន្តាន | សាសនា | បញ្ជូន |

នៅលើសកលលោកមាន ................................ ច្រើន ប៉ុន្តែប្រជាជនកម្ពុជាភាគច្រើនបានប្រកាន់យកសាសនា ................................. ។ នោះគឺដោយសារប្រជាជនយើងមាន ................................. មុតមាំលើព្រះពុទ្ធសាសនា។ នៅថ្ងៃភ្ជុំបិណ្ឌ ខ្មែរយើងយក.................................. ទៅប្រគេនព្រះសង្ឃ ដើម្បី..............................កុសលដល់ញាតិ ............................... ដែលបានចែកឋានទៅ។ នេះមកពីយើង មានជំនឿថា ................................ អាចបញ្ជូនកុសល់ដល់ពួកគាត់មែន។

LIVEWORKSHEETS